ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងសភាព្រហ្មទណ្ឌ
លេខ: ១០៧៩ / ១១-១២-២០១៣
សាលដីកា
លេខ:៥៦ក្រVIIធ/២១-១១-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

៣៣៣*៤៤៤

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦.៧.២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ២១.១១.២០១៤ ដែលមានសមាសភាពដូចតទៅ៖

## សមាសភាពក្រុមប្រឹក្សា

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជីសវនាការ

លោកស្រី **សេង សុគន្ធ**

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១០៧៩ ចុះថ្ងៃទី១១-១២-២០១៣ រវាង:

១-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនហេង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មុខរបរកងរាជអាវុធហត្ថខេត្តរតនៈគិរី ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ ឃុំខ្លួននៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ ដោះលែងថ្ងៃទី២៩-០៨-២០១៣ ។

២-ជនជាប់ចោទឈ្មោះ [redacted] ស្រីវី ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មុខរបរលក់ដូរ ប្តីឈ្មោះ [redacted] មានកូន០២នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ឃុំខ្លួននៅថ្ងៃទី១៦ខែកញ្ញាឆ្នាំ២០១២ ដោះលែងថ្ងៃទី២៩-០៨-២០១៣។

មេធាវីការពារឈ្មោះ [redacted] សុទ្ធារ៉ា

<u>ត្រូវចោទពីបទ:</u> ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនៈគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា.../

២០០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

<u>ដើមបណ្តឹងរដ្ឋប្បវេណីមាន:</u>

១-ឈ្មោះ [redacted] ភេទស្រី អាយុ៦៣ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មុខរបរនៅផ្ទះ ប្តីឈ្មោះ [redacted] មានកូន០៦នាក់។

២-ឈ្មោះ [redacted] ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិឃុំ (មិនចាំ) [redacted] ទីលំនៅសព្វថ្ងៃ [redacted] មុខរបរនៅផ្ទះ ប្តីឈ្មោះ [redacted](ស) មានកូន០២នាក់។

## <u>៦រឿងហេតុមានដូចតទៅ:</u>

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ វេលាម៉ោងប្រហែល១៩ ឈ្មោះ [redacted] ប៊ុនហេង ហៅអេង បានទូរស័ព្ទហៅឈ្មោះ [redacted] សេរីឧត្តម មកជួប (ទូរស័ព្ទហៅចេញ០៩៧ ៣៦៦១០០៧ចូលមកទូរស័ព្ទ ០៩៧ ៧២៥០០០៨៥) មុនពេលឈ្មោះ [redacted] សេរីឧត្តម ចេញពីផ្ទះក៏ប្រាប់ប្រពន្ធថាទៅជួបឈ្មោះ [redacted] មួយភ្លែត ហើយប្រាប់អោយប្រពន្ធកំដៅសម្ល ចាំហូបបាយជុំគ្នា។ ឈ្មោះ [redacted] សេរីឧត្តម ក៏ជិះឡានរបស់ខ្លួនចេញពីផ្ទះមកជួបឈ្មោះ [redacted] ប៊ុនហេង តាមការណាត់។ លុះដល់ម៉ោង១៩និង២០នាទី ប្រពន្ធរបស់ [redacted] សេរីឧត្តម ក៏ទូរស័ព្ទហៅប្តី តែទាក់ទងពុំបាន ក៏ព្យាយាមទូរស័ព្ទបន្តទៅទៀត ក៏ពុំអាចទាក់ទងបានដដែល។ លុះមកដល់ថ្ងៃទី១១ ខែឆ្នាំដដែល សមត្ថកិច្ចនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តរតនៈគិរីបានរកឃើញសព [redacted] សេរីឧត្តម ត្រូវបានគេសម្លាប់ដាក់ចូលក្នុងគូថឡាន(ឡានរបស់ [redacted] សេរីឧត្តម) យកទៅទុកក្នុងចំណុចចំការស្វាយចន្ទីក្នុងភូមិថ្មីយអំពិល ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនៈគិរី។

-បានឃើញចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនហេង ហៅ អេង បានឆ្លើយថា: នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ បានហៅឈ្មោះ [redacted] សេរីឧត្តម មកជួបនៅផ្ទះរបស់ខ្លួន។ ឈ្មោះ [redacted] សេរីឧត្តម បានជិះឡានមកជួបខ្លួនមែន និងបានជជែកពីការរកស៊ីជាមួយគ្នា ដោយសារឈ្មោះ [redacted] សេរីឧត្តម ស្គាល់ថៅកែចិនរកម៉ូយមកទិញគ្រឿងសង្ហារិមធ្វើពីឈើ។ក្នុងពេលនោះខ្លួនក៏សួរទៅឈ្មោះ [redacted] សេរីឧត្តម អំពីការទាក់ទងថៅកែក្នុងការដកប្រាក់មកធ្វើគ្រឿងសង្ហារិមនោះឈ្មោះ [redacted] សេរីឧត្តម ឆ្លើយតបថា គំរោងនោះបរាជ័យហើយដោយសារតែថៅកែមិនឲ្យប្រាក់។ពេលនោះខ្លួនក៏ឃើញមេដៃរបស់ឈ្មោះ [redacted] សេរីឧត្តម ជាប់ស្នាមទឹកតាំប៉ុងថ្មីៗពណ៌ខៀវ ខ្លួនក៏សួរទៅឈ្មោះ [redacted] សេរីឧត្តម ឯងផ្តិតមេដៃរឿងអី ឈ្មោះ [redacted] សេរីឧត្តម ឆ្លើយថា ផ្តិតមេដៃដកប្រាក់ក្នុងរឿងផ្សេងបានប្រាក់២០.០០០ដុល្លា(ពីរម៉ឺនដុល្លាអាមេរិក) ដែលគេរកស៊ីជាមួយអ្នកផ្សេងក្រៅពីខ្លួន។ ខ្លួនក៏សួរទៅឈ្មោះ [redacted] សេរីឧត្តម ថាយកប្រាក់នេះធ្វើអ្វីខ្លះហើយ ឈ្មោះ [redacted] សេរីឧត្តម ថាប្រាក់នេះចាត់ចែងអស់ហើយតែមិនបានកំណត់ថា ចាត់ចែងដល់មុខទំនិញអ្វីមួយច្បាស់លាស់ទេ។ ក្រោយពីឈ្មោះ [redacted] សេរីឧត្តម ចេញពីផ្ទះរបស់ខ្លួនទៅបាត់ហើយ ខ្លួនមិនបានចេញទៅណាភ្លាមទេ គឺខ្លួននៅលេងជាមួយប្រពន្ធ និងកូន រហូតដល់ម៉ោង៦ជាងជិតដល់ ៧/

ម៉ោង៧ ទើបខ្លួនដឹកប្រពន្ធនិងកូនទៅជួយលក់ស៊ុបឱ្យម្ដាយ នៅមុខមន្ទីរព័ត៌មានខេត្ត រហូតដល់ម៉ោង៧ជាង ឈ្មោះតេក បានទូរស័ព្ទហៅខ្លួនទៅហូបអីនៅហាង សារឌី។ខ្លួនក៏ជិះឡានចេញទៅកាន់ហាងនោះដោយបានជួបឈ្មោះតេក ឈ្មោះសឿនឈ្មោះថង ចាន់ណា ជួបប្រពន្ធរបស់ សឿន និងកូនរបស់គាត់ម្នាក់ និងមិត្តភ័ក្រម្នាក់ទៀតមិនចាំឈ្មោះ អង្គុយហូបរួមគ្នា។ ក្រោយពីឈប់ហូបនៅហាងនេះ ក៏បន្តនាំគ្នាទៅច្រៀងខារ៉ាអូខេកាឡាក់ស៊ី មួយកន្លែងទៀត គឺទៅទាំងអស់គ្នា លើកលែងតែប្រពន្ធ និងកូនរបស់ សឿន មិនបានចូលរួមទេ។ក្នុងពេលច្រៀងក្នុងបន្ទប់នោះគ្មានអ្នកថ្មីចូលរួមទៀតទេ ការច្រៀងលេងនេះបានចប់នៅប្រហែលជាម៉ោង ១១យប់ ក៏បែកគ្នាទៅផ្ទះរៀង១ខ្លួន។ ក្នុងពេលមកផ្ទះរៀង១ខ្លួន ខ្លួនដឹងថាឈ្មោះតេក និងឈ្មោះថង ចាន់ណា ទៅដេកផ្ទះនៅវ៉ឺនសៃ ឈ្មោះ សឿន ចេញទៅណាទៀតខ្លួនមិនដឹងទេ ខ្លួនចេញពីច្រៀងមកយកប្រពន្ធនិងកូនទៅដេកនៅផ្ទះ(ហាងម្ហូបទឹកដោះ)មិនចេញទៅណាសោះ ខ្លួននិងឈ្មោះ[redacted]សេរីឧត្តមមានគំរោងរកស៊ីជាមួយគ្នាដោយនាំគ្រឿងសង្ហារឹមទៅលក់នៅប្រទេសវៀតណាម តែមិនទាន់បាននាំចេញទេ។នៅព្រឹកថ្ងៃទី១០ ខ្លួនមិនចាំម៉ោងទេ ប្រពន្ធរបស់ឈ្មោះ [redacted] សេរីឧត្តម មកផ្ទះម្ដាយរបស់ខ្លួន រួចសួរខ្លួនថា មានឃើញប្ដីគាត់ឬអត់កាលពីយប់មិញ ខ្លួនក៏ឆ្លើយប្រាប់ថា អត់ដឹងទេ ខ្លួនឆ្លើយបែបនេះកុំឱ្យប្រពន្ធរបស់ឈ្មោះ[redacted] សេរីឧត្តម ចោទខ្លួនថានាំប្ដីគាត់ដើរលេង រួចប្រពន្ធ[redacted] សេរីឧត្តម ក៏ចេញទៅបាត់ នៅថ្ងៃទី១៣ ឬទី១៤ ខ្លួនក៏បានទៅរើតវ៉ាន់ចេញពីហាងម្ហូបទឹកដោះដោយសារតែខ្លួនឈប់ជួលពីគេ ហើយខ្លួនស្នាក់នៅទីនេះដោយខ្លួនសុំពន្យាពេល ការរុះរើអស់រយៈពេល២ខែហើយ។ ខ្លួនទើបតែបានដឹងថាឈ្មោះ[redacted] សេរីឧត្តម ត្រូវបានគេសម្លាប់ រួចដាក់ក្នុងគូថឡានរបស់វា (ឈ្មោះ [redacted] សេរីឧត្តម) យកទៅទុកចោលក្នុងចំការចន្ទី។ខ្លួនមិនបានចូលរួមបុណ្យសពរបស់ឈ្មោះ[redacted] សេរីឧត្តម ទេ។

-បានឃើញចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] ស្រីវី បានឆ្លើយនៅថា:ក្នុងអំឡុងឆ្នាំ២០១១ ខ្លួននិងឈ្មោះ [redacted] ប៊ុនហេង បានរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ។និងមានគំនិតរកស៊ីលក់ដូរក៏ជួលផ្ទះមួយកន្លែងនៅភូមិទេសអន្លង់ បើកលក់កន្លែងលក់ដូរតែម្ដង មានអ្នករួមទន់ឈ្មោះអាមួយ ភេទស្រីនិងឈ្មោះប៉ូលី (ម្ចាស់ផ្ទះ)សរុបពាហ៊ុន។ ការរកស៊ីនេះមិនបានជោគជ័យទេ ក៏បិទការលក់ដូរនេះតែម្ដង។តែក្រុមគ្រួសាររបស់ខ្លួន សុំបន្តនៅមួយរយៈសិន។ នៅថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១២ ចាប់តាំងពីពេលព្រឹក ខ្លួននិងកូនព្រមទាំងប្ដីនៅផ្ទះជុំគ្នា។ ហើយព្រឹកនោះខ្លួនបានឃើញឈ្មោះ [redacted] សីរីឧត្តម មកផ្ទះខ្លួនជួបនឹងប្ដីខ្លួនតែខ្លួនមិនបានឮពួកគាត់និយាយគ្នាអំពីរឿងអ្វីទេ។ មួយសន្ទុះក្រោយមកឈ្មោះ [redacted] សេរីត្តម ក៏ជិះឡានចេញទៅបាត់ ប្ដីខ្លួនមិនចេញទៅណាទេ។ លុះជិតដល់ម៉ោង៦ល្ងាច ប្ដីខ្លួនបានបើកឡានដឹកខ្លួននិងកូនចេញពីផ្ទះមកជួយលក់ម្ដាយក្មេកខ្លួន។ប្ដីរបស់ខ្លួនគាត់អង្គុយលេងបានមួយស្របក់ គាត់ប្រាប់ខ្លួនថាគាត់ទៅហូបអីនៅហាងតាបារាំង(សារឌី)។ប្រហែលជាម៉ោង១២រំលងអាធ្រាត ខ្លួនក៏ទូរស័ព្ទទៅប្ដី គាត់ប្រាប់ថា គាត់នៅខារ៉ាអូខេ។ពេលគាត់ចេញពីខារ៉ាអូខេ គាត់មកដឹកខ្លួននិងកូន មកដេកនៅផ្ទះ(ហាងម្ហូបទឹកដោះ)វិញទាំងអស់គ្នា។ ក្នុងពេលរៀបដេកនោះខ្លួនបានឮសំលេងឡាន ខ្លួនគិតថា ឡាននោះចូលផ្ទះរបស់ឈ្មោះ ប៉ូលី។ ខ្លួនសូមបញ្ជាក់ថានៅថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០១២ ខ្លួនមិនបានផ្ដល់ចម្លើយថា នៅម៉ោង១២អាធ្រាតបានឮសំរឹបជើងមនុស្ស-ឬក៏ឮស្នូរសំលេងបើកទឹកចេញពីអាង និងបានឃើញមនុស្ស៣នាក់ក្នុងនោះមានឈ្មោះឡៃ នោះឡើយ។

ពាក្យទាំងអស់នេះមានក្នុងកំណត់ហេតុរបស់នគរបាលយុត្តិធម៌ គេចេះតែសរសេរ រួចហើយឱ្យខ្លួនអាន និងផ្តិតមេដៃ។ម្យ៉ាងទៀតគេបញ្ឆោះឱ្យខ្លួនឆ្លើយតាមដែលគេចង់បានទោះទៅគេនឹងឱ្យខ្លួននិងប្តីរួចខ្លួន។ ខ្លួនមិនដឹងទេពេលដែលនគរបាល បានថតសំឡេងរបស់ខ្លួនក្នុងពេលអានកំណត់ហេតុនោះ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ កន គឹមសែន បានឆ្លើយនៅថា: ខ្លួនត្រូវជាប្អូនប្រុសបង្កើតរបស់ឈ្មោះ [redacted] ប៊ុនហេង។ ខ្លួនរស់នៅដាច់ដោយឡែកពីឪពុកម្តាយនិងបងៗ ដោយសារតែខ្លួនមានប្រពន្ធ។ បងរបស់ខ្លួនឈ្មោះ[redacted]ប៊ុនហេង បានបើកហាងលក់ដូរមានភាគហ៊ុន៣នាក់ឈ្មោះ ប៉ូលី ឈ្មោះ អាមួយ និងបងខ្លួន។-ហាងនោះបើកនៅកន្លែងផ្ទះជួលពីឈ្មោះប៉ូលី ហើយបងរបស់ខ្លួនដេករស់នៅក្នុងនេះ។ហាងនេះបើកលក់ដូរបានប្រហែល៥ខែក៏បិទទៅវិញ ដោយសាររកស៊ីមិនចំណេញក្រោយពីបិទហាងនេះ។បងថ្លៃរបស់ខ្លួនក៏អស់ការងារធ្វើ រាល់ពេលទំនេរ ប្តីរបស់គាត់ដឹកមកឱ្យជួយលក់ស៊ុបម្តាយរបស់ខ្លួន។ នៅយប់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ខ្លួនបានដឹងថាបងថ្លៃរបស់ខ្លួន គាត់មកជួយឬមិនបានមកជួយលក់ស៊ុបឱ្យម្តាយរបស់ខ្លួនៗមិនបានដឹងទេ។ នៅព្រឹកថ្ងៃទី១០ ខ្លួនមកផ្ទះម្តាយរបស់ខ្លួនបានឃើញបង អេង និងប្រពន្ធគាត់នាំគ្នាទៅលេងបរកែវ រកទិញឈើគ្រឿងធ្វើផ្ទះ។ចាប់ពីយប់ថ្ងៃទី១០ដល់ទី១២ ខ្លួនមិនដឹងថាបង អេង នៅផ្ទះរបស់គាត់ឬយ៉ាងណាទេ។ តែនៅថ្ងៃទី១២ ប្រហែលជាម៉ោង៥ល្ងាច ប្រពន្ធរបស់ឈ្មោះអេង ហៅខ្លួនមកជួយដឹកឥវ៉ាន់របស់គាត់ចេញពីផ្ទះ(ហាងម្លប់ទឹកដោះ) យកមកទុកនៅផ្ទះរបស់ខ្លួនខ្លះ និងទុកនៅផ្ទះម្តាយរបស់ខ្លួនខ្លះ ពេលខ្លួនទៅដឹកខ្លួនឃើញមានឥវ៉ាន់នៅសល់បន្តិចបន្តួច។ខ្លួននៅចាំថាបងអេង និងបង[redacted] សេរីឧត្តម មានទំនាក់ទំនងស្គាល់គ្នាយូរមកហើយ ដោយឧស្សាហ៍ឃើញឈ្មោះ [redacted] សេរីឧត្តម មកហាងរបស់ខ្លួន។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ សាត់ សឿន ឆ្លើយថា: នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១២ ប្រពន្ធ និងកូនរបស់ខ្លួន មកលេងនឹងខ្លួននៅខេត្តរតនៈគិរី ខ្លួននាំគាត់ទៅលេងជាច្រើនកន្លែង។នៅថ្ងៃទី០៩ ម៉ោងប្រហែលជា៥ល្ងាច ខ្លួនបាននាំប្រពន្ធកូនទៅហូបបាយនៅហាងសាវនី ក្រោយពីរៀបចំមុខម្ហូបរួចស្រេច ខ្លួនទូរស័ព្ទទៅឈ្មោះ [redacted] គេត (ចង់ លិបង៉េត)ហៅ គេត ខ្លួនសួរថាឯងនៅឯណា ប្អូនគេត ប្រាប់ថានៅជាមួយឈ្មោះ[redacted]ចាន់ណា ឈ្មោះស៊ុន និងឈ្មោះឆើត កំពុងហូបសាច់គោអាំង នៅហាងលីហួរ ខ្លួនសួរបន្តថាទៅវ៉ើនសៃឬអត់ ឈ្មោះគេត ប្រាប់ថាទៅវ៉ើនសៃវិញ ខ្លួនក៏ហៅពួកប្អូនៗមកហូបជុំគ្នានៅហាងសាវនី។ នៅប្រហែលជាម៉ោងជិត៧ យប់ឈ្មោះ [redacted] ចាន់ណា ឈ្មោះស៊ុន (គ្រូបង្រៀននៅវ៉ើនសៃ) និងឈ្មោះគេត មកចូលរួមហូបបាយជាមួយ ហើយឃើញឈ្មោះ [redacted] សារ៉េត កំពុងហូបនៅតុក្បែរគ្នា។នៅប្រហែលជាម៉ោង៨ មានគេទូរស័ព្ទមកឈ្មោះគេត ឈ្មោះគេត និយាយថា មិនទៅទេ នៅហូបជាមួយបងសឿន ប្រពន្ធគាត់កូនគាត់។ ខ្លួនក៏សួរគេត ថាអ្នកណាទូរស័ព្ទមកឈ្មោះគេត ប្រាប់ថា ឈ្មោះ អេង ធ្វើPM ខ្លួនប្រាប់ថា បើគង់នឹងផឹកមកផឹកឯណេះមក។ ប្រហែលជាម៉ោង៩ ឈ្មោះ អេង បានមកដល់ ចូលរួមតុជាមួយគ្នា បន្ទាប់មកឈ្មោះអេង ប្រាប់ខ្លួនឱ្យទូរស័ព្ទហៅឈ្មោះឡៃ ឱ្យមកចូលរួមផឹកជាមួយផងឈ្មោះ ឡៃ ក៏មកចូលរួមដែរ តែមកប៉ុន្មាននាក់ខ្លួនពុំចាំទេ។ នៅប្រហែលជាម៉ោងជិតដប់ កូនខ្លួនសុំចេញទៅដេកមុន ខ្លួនក៏ជូនប្រពន្ធនិងកូនទៅកន្លែងដេក រួចត្រឡប់មកផឹកវិញហើយឈ្មោះ ឡៃ ក៏ចេញប្រាក់ជំនួសខ្លួន រួចបបួលទាំងអស់គ្នា./.

ទៅច្រៀងលេងនៅការ៉ាក់ស៊ី ពេលនោះខ្លួនមិនដឹងចប់នៅម៉ោងប៉ុន្មានទេ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះគីង ស៊ាងឡៃ បានឆ្លើយបំភ្លឺថា: នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ចន្លោះម៉ោង៤ទៅ៥ល្ងាច ប្រធានស្នាក់ការស្រុកអូរយ៉ាដាវបានរៀបចំកម្មវិធីហូបចុក ដោយខ្លួនចូលរួមក្នុងកម្មវិធីនេះដែរ។ លុះមកដល់ចន្លោះម៉ោង៧យប់ទៅ៨ជាង ខ្លួននៅស្នាក់ការអូរយ៉ាដាវមិនទាន់ចប់កម្មវិធីទេស្រាប់តែពូសាត សឿន បានទូរស័ព្ទហៅខ្លួនឲ្យទៅចូលរួមហូបបាយជាមួយគាត់នៅហាងតាបារាំង (សាវឌី)ហើយបងតេក ក៏ទូរស័ព្ទហៅខ្លួនបន្ថែមទៀត ដោយខ្លួនស្រវឹងស្រៀងៗបើកឡានមិនកើតក៏ហៅឈ្មោះបញ្ញា វុធ ជាមិត្តភ័ក្ត្ររបស់ខ្លួនឱ្យបើកឡានជូនខ្លួន មកហាងតាបារាំងនេះ មកដល់ម៉ោងប៉ុន្មានមិនបានគិតទេព្រោះស្រវឹងហើយ។ ខ្លួនមកចូលរួមហូបនៅហាងនេះ ខ្លួននៅចាំបានខ្លះ អ្នកចូលរួមផឹកនៅតុតែមួយនោះគឺឈ្មោះតេក ឈ្មោះណា ឈ្មោះអេង ពូសឿន និងមនុស្សស្រី២នាក់។ក្នុងកម្មវិធីនេះពេលហូបចប់ខ្លួនជាអ្នកចេញប្រាក់តែអស់ប៉ុន្មានខ្លួនមិនចាំទេ និងបានបបួលគ្នាទៅច្រៀងនៅការ៉ាក់ស៊ី ដោយមានគ្នាដដែលតែស្ត្រី២នាក់មិនចូលរួមទេ។ ខ្លួនមិនដែលមានទំនាស់ជាមួយឈ្មោះ [redacted] សេរីឧត្តម ម្តងណាឡើយ។ ក្នុងពេលលោក [redacted] សេរីឧត្តម បានចុះផ្សាយព័ត៌មានថាខ្លួន ចាប់ឈើផង និងយកប្រាក់ផងពីអ្នកដឹកឈើនោះ ខ្លួនមិនបានយកចិត្តទុកដាក់ក្នុងរឿងនេះទេ។ អ្នកបើកឡានធ្លាប់ឲ្យខ្លួនបើកឡានទៅកៀឡានរបស់ [redacted] សេរីឧត្តម នៅម្តុំភ្នំកូនមុំ មែន តែពេលកៀភ្លាមនោះខ្លួនមិនដឹងទេ ពេលឡានខ្លួនទៅឆ្ងាយហើយទើបមានគេទូរស័ព្ទប្រាប់ខ្លួន ហើយឪពុកខ្លួនក៏ចេញសោហ៊ុយជួសជុលរួចហើយដែរ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ ថង ចាន់ណា បានឆ្លើយថា: នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ប្រហែលជាម៉ោង៣រសៀលឈ្មោះតេក បានបបួលខ្លួនមកលេងក្រុងបានលុង ពួកខ្លួនទាំង២នាក់មកដល់ក្រុងបានលុងប្រហែលម៉ោង៥ល្ងាច ក៏នាំគ្នាមកហូបសាច់គោអាំងនៅហាងលីហួរ មានគ្នា៤នាក់ឈ្មោះតេក ឈ្មោះផែន វិបុល (ផើត) ឈ្មោះគ្រុប និងរូបខ្លួន។កន្លះម៉ោងក្រោយមកឈ្មោះ តេក ថាទៅហាងសាវឌីទៀតពីព្រោះឈ្មោះសឿន នៅចាំទីនោះ។ពេលទៅហាងសាវឌី មានតែឈ្មោះតេក និងខ្លួនទេ។ ពេលទៅដល់ហាងសាវឌី ខ្លួនឃើញពូសឿន ប្រពន្ធគាត់ កូនរបស់គាត់ អង្គុយចាំនឹងតុដោយរៀបចំឆ្នាំងស៊ុបរួចជាស្រេច ពួកខ្លួនទៅដល់ក៏នាំគ្នាហូបភ្លាមហូបបានប្រហែល១ម៉ោងគឺនៅម៉ោង៧ ខ្លួនក៏ឃើញឈ្មោះ អ៊ិន ប៊ុនហេង មកចូលរួមជាមួយដែរ តែខ្លួនមិនដឹងអ្នកណាហៅគាត់មកទេ។ ប្រហែលជាកន្លះម៉ោងក្រោយមកទៀតខ្លួនឃើញឈ្មោះ គីង ស៊ាងឡៃ មកចូលរួមដែរ តែខ្លួនមិនដឹងអ្នកណាហៅគាត់មកទេ។ ហូបនៅហាងសាវឌីនេះរហូតដល់ម៉ោង៩ជាងទើបឈប់ តែខ្លួនមិនដឹងអ្នកណាចេញប្រាក់ទេ ពីព្រោះខ្លួនដើរមកឡានមុនពេលគិតប្រាក់ រួចនាំគ្នាទៅច្រៀងនៅការ៉ាក់ស៊ីទៀត។ ក្នុងបន្ទប់ច្រៀងនោះខ្លួនឃើញឈ្មោះ [redacted] ប៊ុនហេង ឈ្មោះតេក ឈ្មោះ[redacted] ស៊ានឡៃ ពូ សឿន មនុស្សប្រុសម្នាក់ខ្លួនមិនស្គាល់ឈ្មោះ និងរូបខ្លួន។ ការច្រៀងលេងនេះប្រហែលជាចប់នៅម៉ោងជាង១២យប់ហើយឈ្មោះ[redacted] ស៊ាងឡៃជាអ្នកចេញប្រាក់។ ពេលចប់ខ្លួននិងឈ្មោះ តេក បានទៅដេកនៅផ្ទះវ៉ើនសេរីវិញ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ លឹប តេក ឬ ចង លិបង៉ែត បានឆ្លើយបំភ្លឺថា: នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ប្រហែលជាម៉ោង៥ល្ងាច ខ្លួននិងឈ្មោះ ថង ចាន់ណា នាំគ្នាមកក្រុងបានលុងដោយជិះឡានតែមួយ.../

ខ្លួនជាអ្នកបើក មកជួបពូ សឿន ពីព្រោះគាត់បានណាត់ជាមួយខ្លួន ហូបអីជាមួយប្រពន្ធកូនរបស់គាត់ ។ ពេលពួកខ្លួនទាំង២នាក់មកដល់ក្រុងបានលុងឈ្មោះផែន វិបុល ហៅពួកខ្លួនទាំង២នាក់ទៅហូបអីនៅហាងលីហួរ ដោយសារឈ្មោះ ផែន វិបុល ប្រាប់ថា មិនបានចូលរួមក្នុងការប្រកាសមុខតំណែងខ្លួន។ នៅពេលហូបសាច់គោអាំងនោះមានឈ្មោះថង ចាន់ណា ឈ្មោះផែន វិបុល ឈ្មោះគ្រុប ឈ្មោះស៊ុន និងខ្លួន ហើយនៅម៉ោងប្រហែល៧ជាង ក៏ឈប់ហូបដោយខ្លួនចេញមកហាងសាវឌីហូបបន្តទៀត ដោយឈ្មោះថង ចាន់ណា ឈ្មោះស៊ុន មកជាមួយដែរ។ ពេលហូបនៅហាងសាវឌី មានអ្នកចូលរួម ពូ សឿន ប្រពន្ធនិងកូនគាត់ឈ្មោះ ថង ចាន់ណា ឈ្មោះ ស៊ុន និងខ្លួនក្នុងពេលកំពុងហូបឈ្មោះ[redacted] ប៊ុនហេង បានទូរស័ព្ទមកខ្លួន រួចថានៅឯណា ខ្លួនប្រាប់ថាជាមួយពូ សឿន រួចខ្លួនប្រគល់ទូរស័ព្ទឱ្យពូ សឿន និយាយជាមួយឈ្មោះអ៊ាន ប៊ុនហេង ។ប្រហែលកន្លះម៉ោងក្រោយមកគឺនៅម៉ោង៨ជាង ខ្លួនបានឃើញឈ្មោះអ៊ាន ប៊ុនហេង មកចូលរួមដែរ។បន្ទាប់ខ្លួនឃើញឈ្មោះឡៃ ចូលរួមបន្ថែមទៀត។ ការហូបនេះប្រហែលជាចប់ម៉ោង៩និង៤០នាទី ដោយឈ្មោះឡៃ ជាអ្នកចេញប្រាក់។ហើយនាំគ្នាបន្តទៅច្រៀងនៅកាឡាក់ស៊ី ក្នុងនោះខ្លួនឃើញពូ សឿន ឈ្មោះឡៃ ឈ្មោះ[redacted] ចាន់ណា ឈ្មោះអ៊ាន ប៊ុនហេង និងមិត្តរបស់ឡៃម្នាក់ទៀត។ការច្រៀងលេងនេះចប់នៅម៉ោង១២យប់ ខ្លួននិងឈ្មោះថង ចាន់ណា ត្រឡប់ទៅដេកនៅស្រុកវើនសៃវិញទាំងយប់។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះយឹម សារ៉េត ជានគរបាលយុត្តិធម៌ បានឆ្លើយថា: នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ម៉ោងប្រហែល១៣រសៀល ខ្លួនបានទទួលបញ្ជារពីមេ(នគរបាល)របស់ខ្លួន ឱ្យចុះទៅពិនិត្យមើលរថយន្តមួយគ្រឿងដែលគេចតចោលក្នុងចំការស្វាយចន្ទីក្នុងភូមិចួយអំពិល ឃុំតាអ៊ិង ស្រុកអូរជុំ។ ក្នុងពេលខ្លួនចូលទៅត្រួតពិនិត្យមើលរថយន្តនេះ ស្រាប់តែមានក្លិនស្អុយចេញពីរថយន្តនោះ និងពិនិត្យមើលជុំវិញកន្លែងចតរថយន្តនេះពុំឃើញមានអ្វីបន្សល់ទុកទេ និងគ្មានស្នាមអ្វីគួរឱ្យកត់សម្គាល់ដែរ សូម្បីតែស្នាមកង់រថយន្តក៏ត្រូវលុបបាត់ដែរដោយសារតែភ្លៀង៣ថ្ងៃជាប់ៗគ្នា គឺថ្ងៃទី០៩ ដល់ថ្ងៃទី១១ ចំពោះតួរថយន្តវិញមានស្នាមប្រលាក់ម្រាមដៃដែរ មានស្នាមប្រលាក់ពណ៌ក្រហមក្រម៉ៅ។ ចំពោះខាងក្នុងរថយន្តវិញមានប្រលាក់ឈាមពីកន្លែងគ្រង់កៅអី និងកន្លែងបើកទ្វាររថយន្ត។ ចំពោះខាងក្នុងនៃគូថរថយន្តវិញមានសាកសព([redacted] សេរីឧត្តម) ដេកផ្កាប់មុខ ដោយគ្របក្រណាត(សំពត់គ្របរថយន្ត)ពីលើ មិនសូវមានឈាមទេ ខោ អាវ របស់សព ប្រលាក់ដីទាំងអស់។ នៅថ្ងៃទី១២បានស្រាវជ្រាវឃើញស្បែកជើងសង្រែកមួយគូរដែលបន្សល់ទុក នៅចម្ងាយប្រហែល២០ម ទៅ៣០ម ពីផ្ទះរបស់ឈ្មោះអេង និងបានចាប់យកមកបង្ហាញប្រពន្ធជនរងគ្រោះ ហើយគាត់អះអាងថា ស្បែកជើងប្តីរបស់គាត់។នៅថ្ងៃទី១៣តំណាងអយ្យការបានដឹកនាំចុះទៅត្រួតពិនិត្យមើលក្នុងលំនៅឋាន(ហាងម្លប់ទឹកដោះ)របស់ឈ្មោះ អេង ដោយបានចាប់យកសំណាកកំរាលពូក ក្រៅពីនេះមិនបានយកអ្វីទេ។ វត្ថុតាងដែលបានចាប់យកពីក្នុងរថយន្ត និងក្នុងផ្ទះនោះត្រូវបានបញ្ជូនទៅនាយកដ្ឋាននៃក្រសួងមហាផ្ទៃ ដើម្បីធ្វើកោសល្យវិច្ច័យ ដោយខេត្តរតនគិរីមិនមានលទ្ធភាពធ្វើទេ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ ហ្វង ប៊ុនថាណម ជានគរបាលយុត្តិធម៌ បានឆ្លើយថា: នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ម៉ោងប្រហែល១៣ ខ្លួនបានចូលរួមពិនិត្យរថយន្តរបស់សព ក្នុងពេលពិនិត្យស្ថានភាពលើដីគ្មានអ្វីទេ សូម្បីតែស្នាមកង់រថយន្តនេះក៏គ្មានដែរដោយសារតែទឹកភ្លៀង តួរថយន្តមានស្នាមប្រឡាក់ តែមិនដឹងជា-/.

ស្នាមអ្វីផ្នែកខាងក្នុងរថយន្តខ្លួនមិនបានចូល ពិនិត្យទេដោយសារមានក្លិនស្អុយខ្លាំងពេក។នៅថ្ងៃទី១២ ម៉ោងប្រហែល ១០ ខ្លួនបានចូលរួមពិនិត្យនៅក្បែរផ្ទះរបស់ឈ្មោះអេង ប្រទះឃើញស្បែកជើងសង្រែកមួយគូរ ឋិតនៅចម្ងាយប្រ-ហែលពី៣០ម ទៅ៤០ម ពីផ្ទះនេះ និងបានយកស្បែកជើងនេះមកបង្ហាងប្រពន្ធជនរងគ្រោះ ហើយគាត់អះអាងថាជាស្បែកជើងរបស់ប្ដីគាត់មែន។នៅថ្ងៃទី១៣ប្រហែលម៉ោង៩ព្រឹក ដោយមានការដឹកនាំដោយតំណាងអយ្យការចូលទៅពិនិត្យលំនៅឋាន(ហាងម្លប់ទឹកដោះ)របស់ឈ្មោះអេង ខ្លួនបានចូលរួមដែរ។ពេលត្រួតពិនិត្យលំនៅឋាននេះឈ្មោះអេង បានរើតវ៉ាន់ចេញអស់ ក្នុងនោះបានចាប់យកកំរាលពូកទៅធ្វើកោសល្យវិច្ច័យ ដោយសារពូកនេះមានក្លិនថ្នាប-ប្រហែលឈាមដែរ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ វណ្ណ ថន បានឆ្លើយថាៈ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១២ ខ្លួនបានឈរជើងនៅស្នាក់ការលេខ៧៨២ ស្ថិតនៅចំណុចអូរយ៉ាដាវពេញមួយថ្ងៃ។ នៅថ្ងៃនោះវេលាម៉ោងប្រហែល៥ល្ងាចមានកម្មវិធីជួបជុំហូបចុកលេងក្នុងស្នាក់ការលេខ៧៨២របស់ខ្លួនដែលមានមនុស្សចូលរួមប្រហែលជា១០នាក់ ហើយពេលមានប្រជាពលរដ្ឋនៅក្បែរនោះបួន ប្រាំនាក់ចូលរួមដែរ។ នៅល្ងាចនោះដែរឈ្មោះ គឹង ស៊ាងឡៃ និងមិត្តភ័ក្តគេម្នាក់ឈ្មោះ បញ្ញា វុទ្ធ ហៅ ជ្រុញ ក៏បានចូលរួមហូបចុកដែរ។ ការហូបចុកនេះគឺហូបរហូតដល់ម៉ោងប្រហែលដប់ជាងយប់ទើបឈប់។ ដោយឡែកឈ្មោះ គឹង ស៊ាងឡៃ និងមិត្តភ័ក្តគេឈ្មោះ បញ្ញា វុទ្ធ ហៅ ជ្រុញ មិនបាននៅហូបចុកដល់ម៉ោងដប់ជាងទេ គឺនៅម៉ោងប្រហែលជាប្រាំបីជាងយប់ បានចេញពីកន្លែងហូបចុកមុនគេ ប៉ុន្តែខ្លួនមិនបានដឹងថាពួកគាត់ទៅណាទេ។ ចំពោះការស្លាប់របស់អ្នកការសែតឈ្មោះ[redacted] សេរីឧត្តម នោះខ្លួនមិនបានដឹងទេ ហើយខ្លួនបានដឹងនៅពេលសារព័ត៌មានផ្សព្វផ្សាយ និងមុខរបររកស៊ីអ្វីខ្លះ ខ្លួនមិនបានដឹងដែរ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ សាន ម៉ារ៉ាឌី បានឆ្លើយថាៈ ខ្លួនជាកូនរបស់ឈ្មោះ [redacted] សេរីឧត្តម ខ្លួនមិនបានចាំថ្ងៃខែណាទេ ក្នុងឆ្នាំ២០១២ ម៉ោងប្រហែលពី៦ទៅ៧យប់ ខ្លួន ស៊ីញ៉ូទូរស័ព្ទមកឪពុកខ្លួន ភ្លាមនោះឪពុកខ្លួនទូរស័ព្ទមកខ្លួនភ្លាមដែរ ដោយគាត់និយាយតែមួយម៉ាត់ថា គាត់រវល់មួយភ្លែត ខ្លួននិងឪពុកក៏មិនទាន់បិទទូរស័ព្ទភ្លាមដែរ ខ្លួនបានឮសំឡេងក្នុងទូរស័ព្ទនោះថា ឥឡូវបងឯងចង់យ៉ាងម៉េច! និងឮសំឡេងតបថា អត់ចង់យ៉ាងម៉េចទេ! ពេលនោះទូរស័ព្ទក៏ដាច់សំឡេងបាត់។សំឡេងដែលបានឮក្នុងទូរស័ព្ទនេះ ជាសំឡេងរបស់មនុស្សប្រុសក្នុងស្ថានភាពមិនល្អនឹងគ្នា។ខ្លួនឧស្សាហ៍ស៊ីញ៉ូទូរស័ព្ទទៅឪពុក ពីព្រោះកន្លងមកគាត់ប្រាប់ឲ្យខ្លួនស៊ីញ៉ូទៅគាត់ គាត់នឹងទូរស័ព្ទមកវិញភ្លាមមិនដែលយូរទេ។ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ម៉ោង១២ថ្ងៃត្រង់ ខ្លួនបានទទួលដំណឹងពីបងប្រុសរបស់ខ្លួនប្រាប់ថា ឪពុកយើងស្លាប់ហើយ។ ខ្លួនបានមកចូលរួមបុណ្យឪពុកដែរ។

-បានឃើញចម្លើយសាក្សីឈ្មោះអ៊ិន ប៊ូលី បញ្ជាក់ថាៈ ខ្លួនមានផ្ទះមួយកន្លែងនៅក្បែរហាងម្លប់ទឹកដោះនេះដែរ ហាងម្លប់ទឹកដោះនេះបើករកស៊ីមានគ្នា៣នាក់ គឺ១ រូបខ្លួន ២ឈ្មោះអ៊ាន ប៊ុនហេង និង៣ឈ្មោះ អាមួយ។ទីតាំងហាងនេះ គឺជួលពីរូបខ្លួន។ដំណើរការហាងនេះបានរយៈពេលតែ៣ខែ ក៏ក្ស័យធន ក៏បិទហាងនេះ តែឈ្មោះ អ៊ានប៊ុនហេង និងប្រពន្ធឈ្មោះ[redacted] ស្រីវី រស់នៅក្នុងហាងដដែលមិនចេញទៅណាទេ។នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១២ ប្រហែលជាម៉ោង៦ល្ងាច ខ្លួនចេញពីផ្ទះទៅភ្នំពេញ ដោយជិះរថយន្តឈ្នួល និងឲ្យឈ្មោះថៃ នៅយាមផ្ទះនេះឲ្យខ្លួន

រហូតដល់ពេលខ្លួនមកវិញ។នៅថ្ងៃទី១២ ខ្លួនចេញពីភ្នំពេញមកផ្ទះវិញ ពេលធ្វើដំណើរមកដល់មុំអូរពងមាន់ ស្រាប់ឈ្មោះ[redacted] ស្រីវី ទូរសព្ទ័ប្រាប់ខ្លួនថា គាត់ឈប់ជួលផ្ទះ(ហាងម្ហូបទឹកដោះ)នេះទៀតហើយ គាត់គ្មានលទ្ធភាពបង់ថ្លៃជួលទៀតទេ ខ្លួនសុខចិត្តឱ្យឈ្មោះ[redacted] ស្រីវី រើឥវ៉ាន់ចេញ នៅប្រហែលម៉ោង៤ល្ងាចខ្លួនទៅមើលហាងនោះ ឈ្មោះ[redacted] ស្រីវី រើឥវ៉ាន់ចេញអស់ហើយ នៅសល់តែធាន ឆ្នាំង កៅអីជ័រ និងកាំបិតចិតបន្លែ ដែលគរទុក។

-បានឃើញចម្លើយសាក្សីឈ្មោះរស់ សម្បូរ បញ្ជាក់ថា: ខ្លួនធ្លាប់ស្គាល់ឈ្មោះអ៊ិន ប៊ុនហេង និងឈ្មោះ[redacted]សេរីឧត្តម ប្រហែលមួយឆ្នាំកន្លងមកហើយ។ក្នុងខែសីហានេះ ឈ្មោះ[redacted]សេរីឧត្តម និងឈ្មោះ អ៊ិន-ប៊ុនហេង និងរូបខ្លួន បានរួមគ្នាពិភាក្សាអំពីការរកស៊ីលក់គ្រឿងសង្ហារិមធ្វើអំពីឈើ ដោយព្យាយាមជួបគ្នាពី២ទៅ៣ដងដែរ តែមិនទាន់ស្រេចនៅឡើយទេ។គំរោងនោះគឺខ្លួនមានគ្រឿងសង្ហារិម ឈ្មោះអ៊ិន ប៊ុនហេង ស្គាល់អ្នកដឹកចេញទៅប្រទេសវៀតណាម ឈ្មោះហង្ស សេរីឧត្តម ស្គាល់អ្នកទិញនៅប្រទេសវៀតណាម។ក្នុងខែកញ្ញា ឆ្នាំ២០១២ ខ្លួនទទួលដំណឹងថាឈ្មោះ[redacted] សេរីឧត្តម ត្រូវបានគេសម្លាប់ចោល។កន្លងមកខ្លួនធ្លាប់ឮឈ្មោះអ៊ិន ប៊ុនហេង និយាយថា ឈ្មោះឡៃ(គីង ស៊ាងឡៃ) និងឈ្មោះ[redacted] សេរីឧត្តម មិនត្រូវគ្នាទេ ពីព្រោះអ្នកទាំង២នាក់នេះធ្លាប់ប៉ះ(គ្រោះថ្នាក់ចរាចរ)ឡាន នៅថ្ងៃទី០៩-០៩-២០១២ ម៉ោង១៣ ខ្លួនបានឃើញឡានរបស់ឈ្មោះ[redacted] សេរីឧត្តម នៅស្រុកអូរយ៉ាដាវ ខ្លួនក៏ទូរស័ព្ទសួរឈ្មោះ[redacted] សេរីឧត្តម ប្រាប់ថា ទៅវៀតណាមជួបថៅកែ រួចខ្លួនក៏បិទទូរស័ព្ទ លុះដល់ម៉ោង៤ល្ងាច ខ្លួនទូរស័ព្ទមកឈ្មោះ[redacted]សេរីឧត្តម ម្តងទៀតដើម្បីសួរដំណឹង មកពីព្រំដែនវិញហើយឬនៅ ឈ្មោះ[redacted]សេរីឧត្តម ប្រាប់ថា មកដល់ក្រុងបានលុងវិញហើយ និងថាទៅមើលឥវ៉ាន់បន្តិច ខ្លួនឈប់សួររួចបិទទូរស័ព្ទ។លុះថ្ងៃទី១០ម៉ោង៩ព្រឹកខ្លួនទូរស័ព្ទមកឈ្មោះ[redacted]សេរីឧត្តម ក៏លែងចូល លុះម៉ោង៩យប់ មានអ្នកកា-សែតអាស៊ីអគ្នេយ៍ទូរស័ព្ទមកខ្លួន សួររកឈ្មោះ[redacted] សេរីឧត្តម ខ្លួនប្រាប់មិនដឹងទេ ពីព្រោះមុននេះខ្លួនទូរស័ព្ទមកឈ្មោះ[redacted]សេរីឧត្តម មិនចូលដែរ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ ជា គន្ធា បានឆ្លើយថា: ខ្លួនជាមេការក្នុងហាងសាវន៍។ នៅថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១២ ម៉ោងប្រហែលពី៧យប់ឬ៨យប់ ឈ្មោះសាត់ សឿន ហៅ សឿន ផែនដី បានចូលមកហូបក្នុងហាងនេះ ដំបូងតុគាត់មានគ្នា៣នាក់ (សាត់ សឿន ប្រពន្ធគាត់ និងកូនស្រីគាត់) ប្រហែលកន្លះម៉ោងក្រោយមកទៀត មានមនុស្ស៣នាក់ទៀតចូលមកទៀតរួមតុជាមួយគាត់ ខ្លួនមិនស្គាល់ពួកគាត់ទាំងបីនាក់នោះទេ។នៅកន្លែងតុឈ្មោះ សាត់ សឿន ខ្លួនឃើញឈ្មោះ អ៊ិន ប៊ុនហេង ចូលរួមផឹកជាមួយដែរនៅម៉ោងប្រហែល៨យប់។ប្រហែលជាម៉ោង៨:៣០នាទី ឬ៩ ឈ្មោះសាត សឿន បានឱ្យដឹកប្រពន្ធនិងកូនចេញពីកន្លែងនេះ ក្រៅពីនោះនៅផឹកតុដដែលនិងមានអ្នកមកពីខាងក្រៅចូលរួមផឹកក្នុងតុថែមទៀត។ អ្នកចូលមកជាបន្តបន្ទាប់នោះខ្លួនលែងចាំបានហើយ។ អ្នកផឹកនៅតុនោះបានចាក់ចេញឈប់ផឹកនៅម៉ោងប្រហែល១០ ឬ១១ ។ ចំពោះការស្លាប់របស់ឈ្មោះ[redacted]សេរីឧត្តម គ្មានអ្នកណានិយាយគ្នាអំពីរឿងនោះទេ ហើយខ្លួនក៏មិនដឹងរឿងនោះដែរ។

-បានឃើញចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ រស់ ថងសុទ្ធ បានឆ្លើយថា: ចំការចន្ទីនោះជារបស់កូនរបស់ខ្លួនដែរវាបានទិញពីគេ រួចផ្ញើរទុកឱ្យខ្លួនជួយមើល ក្នុងការប្រមូលផលម្តង១គឺជួលឱ្យគេប្រមូលទាំងស្រុង និងបានមក.../

ពិនិត្យមើលក្នុងពេលប្រមូលផល ក្រៅពីនោះពុំដែលមកទេ។ ចំពោះរឿងយករថយន្តទៅទុកចោលក្នុងចំការចន្ទីនោះ ខ្លួនទើបនឹងក្នុងអំឡុងខែធ្នូ ឆ្នាំ២០១២ ប៉ុណ្ណោះ។

-បានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះអ៊ុម ចន្ទី បានឆ្លើយថា: ខ្លួនត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] សេរីឧត្តម ។ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ម៉ោងប្រហែល៦ល្ងាច ប្តីខ្លួនត្រឡប់ពីធ្វើការមកផ្ទះ គាត់បានសម្រាក់មួយភ្លែតក៏មានគេទូរស័ព្ទមកប្តីគាត់និយាយគ្នាចប់ ក៏ប្រាប់ខ្លួនថា គាត់ចេញទៅក្រៅមួយភ្លែតពីព្រោះឈ្មោះ អេង ទូរស័ព្ទហៅឱ្យទៅជួប។ប្តីក៏ប្រាប់អោយខ្លួនកំដៅសម្ល និងចាំហូបបាយជុំគ្នា។ខ្លួនចាំប្តីរហូតដល់ម៉ោង៧និង៣០នាទី ក៏ទូរស័ព្ទទៅប្តីតែមិនចូលសោះក៏ព្យាយាមទូរស័ព្ទជាច្រើនលើកនៅតែមិនចូល ខ្លួនក៏សម្រេចចិត្តហូបបាយមុន។

-បានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះកែវសុវណ្ណ បានឆ្លើយថា:នៅថ្ងៃទី៩-៩-២០១២ វេលាម៉ោងប្រហែល៦ល្ងាច ឈ្មោះឧត្តម បានគេពីខេត្តរតនៈគីរីទៅជួបប៉ាបង្កើត គឺគេទូរស័ព្ទលើតុ នៅឯស្រុកភូមិចំការឪឡឹក ខណៈពេលនោះខ្លួនកំពុងធ្វើម្ហូប ហើយប្តីខ្លួនក៏បានទៅលើកទូរស័ព្ទនិយាយជាមួយកូន ពេលនោះខ្លួនបានឮសំឡេងកូនសួរទៅឪពុករបស់វាថា ប៉ាបានម្ហូបអី? ហើយប្តីខ្លួនបានប្រាប់ថា ម្ហូបអីទេព្រោះម៉ាកកំពុងធ្វើ ហើយប្តីខ្លួនក៏សួរកូនចង់ជួបម៉ាកឬអត់ ហើយកូនខ្លួនក៏ប្រាប់ថាប៉ុណ្ណឹងបានហើយ ខ្លួនជាប់រវល់ហើយ រួចក៏បិទទូរស័ព្ទទៅ។លុះដល់ថ្ងៃទី១១-៩-២០១២ ខ្លួនបានទទួលដំណឹងពីកូនប្រសារ ប្រាប់តាមទូរស័ព្ទថាកូនឧត្តមស្លាប់ហើយ។ នៅក្នុងរឿងនេះខ្លួនសំណូមពរឱ្យតុលាការជួយរកយុត្តធម៌ឱ្យកូនខ្លួន និងសំណូមពរឱ្យតុលាការផ្តល់រថយន្តមកខ្លួន ដើម្បីបានចាត់ធ្វើបុណ្យសពកូន និងឯកភាពចំពោះការទាមទារសំណងចំនួន១០ម៉ឺនដុល្លាអាមេរិក ដូចការទាមទាររបស់កូនប្រសារខ្លួនដែរ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៥(ខ) ចុះថ្ងៃទី ២៨-០៨-២០១៣ របស់សាលាដំបូងខេត្តរតនៈគិរី ដែលបានសំរេចសេចក្តីដូចខាងក្រោម:

-អោយឈ្មោះ អ៊ាន ប៊ុនហេង និងឈ្មោះ ស៊ឹម ស្រីវី (អត្តសញ្ញាណខាងលើ) រួចខ្លួនពីបទចោទពីបទ មនុស្សឃាដគិតទុកជាមុន នៅភូមិជ្រួយអំពិល ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ តាមមាត្រា៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣៥១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែឆ្នាំដដែល ចំពោះមុខឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ស្រីវី និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តែកំបាំងមុខឈ្មោះ [redacted] សុវណ្ណ ។

បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញពាក្យបណ្តឹងឧទ្ធរណ៍លេខ១៣ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បានប្តឹងត្រង់ចំណុចទាំងមូលនៃសាលក្រម ។

-បានឃើញរបាយការណ៍ចុះថ្ងៃទី០៥-០៣-២០១៤ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

-បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី០៨-០៥-២០១៤ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

-ឈ្មោះ [redacted] ប៊ុនហេង (វត្តមាន)

-ឈ្មោះ [redacted] ស្រីវី (វត្តមាន)

មានមេធាវីការពារឈ្មោះ [redacted] សុទ្ធារ៉ា (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាធ្វើការអធិបាយសង្ខេបរឿង

តំណាងមហាអយ្យការបានឆ្លើយថា: ក្រោយពីបានឮថាឱ្យជនជាប់ជនទាំងពីរនេះរួចផុតពីបទចោទ ទើបអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ក៏បានប្តឹងឧទ្ធរណ៍មក ដើម្បីឱ្យក្រុមប្រឹក្សាសភាព្រហ្មទណ្ឌធ្វើការអង្កេតឡើងវិញ។

-ឈ្មោះ អ៊ាន ប៊ុនហេង បានឆ្លើយថា: ខ្លួនមានអាយុ៣៧ឆ្នាំ មានទីលំនៅភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនៈគីរី ខ្លួនធ្លាប់រកស៊ីជាមួយគាត់ដែរ តែពេលមួយឃើញគាត់មានស្នាមមេដៃប្រលាក់ត្រា ខ្លួនក៏សួរ គាត់ឆ្លើយថា គាត់បានផ្តិតមេដៃទទួលលុយ២ម៉ឺនដុល្លា ហើយគាត់ប្រាប់ថាការងារយើងបរាជ័យហើយ ខ្លួនក៏ឈប់សួរទៅ។រួចបែកគ្នាទៅហូបស៊ុបជាមួយសាត សឿន ហៅសឿន ផែនដី ។អ្នកទៅហូបស៊ុបមានឈ្មោះសឿន ប្រពន្ធសឿន និងកូនគាត់ ព្រមទាំងជនជាតិឡាវម្នាក់ទៀត។ចំពោះស្បែកជើងដែលគេរកឃើញ គេថាជាស្បែកជើងរបស់ជនរងគ្រោះ តែខ្លួនមិនដឹងថាជាស្បែកជើងជនរងគ្រោះឬក៏មិនមែន ព្រោះទីនោះជាកន្លែងលេងបាល់ និងជាកន្លែងគំនរសំរាម។ស្បែកជើងនោះនៅជិតតារាងបាល់ ខ្លួនរកស៊ីជាមួយសេរីឧត្តម និងឈ្មោះសំបូរ ហើយការនិយាយគ្នាវែងៗអញ។

**សំណូមពរ:** សុំតម្កល់សាលក្រមរបស់សាលាដំបូងខេត្តរតនៈគីរីទុកនៅដដែល។

-ឈ្មោះ [redacted] ស្រីវី បានឆ្លើយថា: គេដាក់ក្រដាសសរសេរហើយ ឱ្យខ្លួនអាន ហើយនិយាយតាមក្រដាសដែលសរសេរនោះ ហើយប្រាប់ថា ខ្លួនអានហើយឱ្យទៅផ្ទះវិញ។ ខ្លួនពុំដឹងរឿងអ្វីទេ សុំតុលាការតម្កល់សាលក្រមរបស់តុលាការខេត្តរតនៈគីរីទុកនៅដដែល។

-តំណាងមហាអយ្យការធ្វើការសន្និដ្ឋាន:

ពាក់ពន្ធ័ក្នុងការរកស៊ីផលប្រយោជន៍ តែពុំឃើញមានការបាត់បង់ទ្រព្យសម្បត្តិដែលបង្កជាហេតុនោះទេ។ទីមួយទូរស័ព្ទ ក៏ពុំមានឯកសារណាដែលពាក់ពន្ធ័និងផលប្រយោជន៍ ទើបធ្វើការអង្កេត។កូនរបស់ជនរងគ្រោះបានទូរស័ព្ទទៅឪពុក តែឪពុកពុំបាននិយាយអ្វីទេ គ្រាន់តែឮការជជែក។ មួយទៀតរឿងស្បែកជើងថាជាស្បែកជើងរបស់ជនរងគ្រោះ តែក៏ពុំទាន់ច្បាស់ដែរ ហើយចំពោះពូកប្រឡាក់ឈាម ក៏យកទៅធ្វើកោសល្យវិច្ច័យដល់ទៅប្រទេសវៀតណាម ហើយបញ្ជាក់ថា:មិនមែនជាឈាមទេ។ហើយចំពោះក្រយ៉ៅដៃក៏ពុំមានការស៊ើបអង្កេតបានច្បាស់លាស់ដែរ ការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរនេះ។ ចំពោះឈ្មោះស៊ុម ស្រីវី ដូចជានៅឆ្ងាយពីការស៊ើបអង្កេតនេះ ហើយចំពោះឈ្មោះ./

អ៊ាន ប៊ុនហេង គឺស្ថិតក្នុងការសង្ស័យនៅឡើយ។ហេតុនេះសុំក្រុមប្រឹក្សាពិនិត្យនឹងសម្រេចទៅតាមច្បាប់។

-មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] សុទ្ធារ៉ា ធ្វើការសន្និដ្ឋាន:

កូនក្តីខ្លួននៅហាងលក់ស៊ីបរបស់គាត់ ហើយនៅម៉ោងដែលកើតហេតុនេះ គាត់បានចេញទៅខាងក្រៅខោបាត់ ហើយ ចំពោះទូរស័ព្ទដែលកូនជនរងគ្រោះឮថា បងឯងចង់យ៉ាងម៉េច? ហើយស្បែកជើងដែលជាភស្តុតាង គឺបញ្ជាក់ថា ប្រពន្ធគាត់ថា ស្បែកជើងប្តីគាត់ពណ៌ឈាមជ្រូក តែស្បែកជើងយកមកបង្ហាញពណ៌ខ្មៅ ហើយលោកសំបូរ គាត់ជាអ្នកលក់គ្រឿងសង្ហារឹម។ ការចោទប្រកាន់មកលើកូនក្តីខ្លួនទាំងពីររូបនេះមិនមានភស្តុតាងទាល់តែសោះ ដូច្នេះ ផ្អែកលើមាត្រា៣៨ និងមាត្រា៣៥១ នៃក្រមនិតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់-ចោទ។

សំណូមពរ: សុំកំកល់សាលក្រមលេខ ២៥(ខ) ចុះថ្ងៃទី២៨-០៨-២០១៣ ទុកជាបានការដដែរ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឆ្លើយឱ្យការណ៍និងប្តឹងសុំ

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន

-ក្រោយពីបានស្តាប់មេធាវីសន្និដ្ឋាន

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់។

**<u>សាលាឧទ្ធរណ៍យល់ឃើញថា:</u>**

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២១-១១-២០១៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ៣៧៥ និងមាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-កាលពីព្រលប់ថ្ងៃទី០៩-០៩-២០១២ វេលាម៉ោងប្រហែល១៩ ជនរងគ្រោះឈ្មោះ [redacted] សេរីឧត្តម បានចេញដំណើរពីផ្ទះរបស់ខ្លួនស្ថិតនៅភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនៈគីរី ដោយជិះរថយន្តរបស់ខ្លួន ហើយបានប្រាប់ប្រពន្ធថាទៅជួបឈ្មោះ អេង មួយភ្លែត។ លុះដល់ម៉ោងប្រហែល១៩ និង២០នាទី ប្រពន្ធជនរងគ្រោះបានទូរស័ព្ទហៅប្តី តែទាក់ទងពុំបាន ហើយជនរងគ្រោះក៏បាត់ដំណឹងរហូតដល់ថ្ងៃទី១១-០៩-២០១២ ប្រជាជន និងសមត្ថកិច្ចនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តរតនៈគីរីបានប្រទះឃើញរថយន្តរបស់ជនរងគ្រោះចតចោលនៅក្នុងចំការស្វាយចន្ទី ស្ថិតនៅក្នុងភូមិថ្មយអំពិល ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនៈគីរី ហើយក៏បានឃើញសពជនរងគ្រោះឈ្មោះ [redacted] សេរីឧត្តម ត្រូវឃាតករសម្លាប់ដាក់គូថរថយន្តរបស់ខ្លួន។ ក្រោយពីបានធ្វើការអង្កេតបឋមសមត្ថកិច្ចបានដាក់ការសង្ស័យទៅលើឈ្មោះអ៊ាន ប៊ុនហេង និងប្រពន្ធឈ្មោះ [redacted] ស្រីវី ហើយសមត្ថកិច្ចក៏បានធ្វើការស្រាវជ្រាវ ដោយបានរកឃើញស្បែកជើងមួយគូរ និងបានដកហូតកម្រាលពូកដែលមានស្នាមប្រឡាក់ដែលសង្ស័យថាជាឈាមជនរងគ្រោះ ពីផ្ទះរបស់ជនជាប់ចោទឈ្មោះអ៊ាន ប៊ុនហេង និង [redacted] ស្រីវី។

៣-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនហេង បានឆ្លើយថា នៅថ្ងៃទី០៨-០៩-២០១២ ខ្លួនបានទូរស័ព្ទហៅឈ្មោះ

[redacted] សេរីឧត្តម មកជួបនៅផ្ទះរបស់ខ្លួន ហើយឈ្មោះ [redacted] សេរីឧត្តមបានមកជួបខ្លួនមែន និងបានជជែកគ្នាពីការរកស៊ីជាមួយគ្នា ដោយសារឈ្មោះ [redacted] សេរីឧត្តម ស្គាល់ថៅកែចិនរកម៉ូយមកទិញគ្រឿងសង្ហារិមធ្វើពីឈើ។ក្នុងពេលនោះខ្លួនសួរទៅឈ្មោះ [redacted] សេរីឧត្តម ឆ្លើយតបថាគម្រោងនោះបរាជ័យហើយ ដោយសារតែថៅកែមិនឱ្យប្រាក់។ពេលនោះខ្លួនក៏ឃើញមេដៃរបស់ឈ្មោះ [redacted] សេរីឧត្តម ជាប់ស្នាមទឹកតាំប៉ុងថ្មីៗ ខ្លួនក៏សួរទៅឈ្មោះ [redacted] សេរីឧត្តម ឯងផ្តិតមេដៃរឿងអី ឈ្មោះ [redacted] សេរីឧត្តម ឆ្លើយថាផ្តិតមេដៃដកប្រាក់រឿងផ្សេង បានប្រាក់២០.០០០$ (ពីរម៉ឺនដុល្លា)ដែល តែរកស៊ីជាមួយអ្នកផ្សេងក្រៅពីខ្លួន។ក្រោយពីឈ្មោះ [redacted] សេរីឧត្តម ចេញពីផ្ទះរបស់ខ្លួន ខ្លួនពុំបានចេញទៅណាភ្លាមទេ គឺនៅលេងជាមួយប្រពន្ធ និងកូនរហូតដល់ម៉ោង០៦ជាងជិតដល់០៧(ល្ងាច) ទើបខ្លួនដឹកប្រពន្ធកូនទៅជួយលក់ស៊ុបឱ្យម្តាយនៅមុខមន្ទីរព័ត៌មានខេត្តរហូតដល់ម៉ោង០៧ជាង ឈ្មោះតេក បានទូរស័ព្ទហៅខ្លួនទៅហូបអីនៅហាង សារឌី។ខ្លួនជិះរថយន្តទៅកាន់ហាងនោះដោយបានជួបឈ្មោះតេក ឈ្មោះសឿន ឈ្មោះថង ចាន់ណា ជួបប្រពន្ធរបស់ឈ្មោះសឿន និងកូនរបស់គាត់ម្នាក់ និងមិត្តភក្រ័ម្នាក់ទៀតមិនចាំឈ្មោះ អង្គុយហូបជុំគ្នា។ក្រោយពីឈប់ហូបនៅហាងនោះក៏បន្តទៅច្រៀងខារ៉ាអូខេ នៅកាឡាក់ស៊ីមួយភ្លែតទៀត គឺទៅទាំងអស់គ្នា លើកលែងតែប្រពន្ធ និងកូនរបស់ឈ្មោះសឿន មិនបានចូលរួមទេ។ការច្រៀងលេងនេះបានចប់នៅម៉ោងប្រហែលជា១១យប់ ក៏បែកគ្នាទៅផ្ទះរៀងៗខ្លួន។ ពេលចេញពីច្រៀងខ្លួនទៅយកប្រពន្ធ និងកូនទៅដេកនៅផ្ទះ(ហាងម្លប់ដើមទឹកដោះគោ)មិនបានចេញទៅណាសោះ។

៤-ជនជាប់ចោទឈ្មោះ [redacted] ស្រីរី បានឆ្លើយបញ្ជាក់ថា នៅថ្ងៃទី០៩-០៩-២០១២ ចាប់តាំងពីពេលព្រឹកខ្លួន និងកូនព្រមតាំងប្តីនៅផ្ទះជុំគ្នា ខ្លួនបានឃើញឈ្មោះ [redacted] សេរីឧត្តម មកផ្ទះខ្លួនជួបនឹងប្តីខ្លួន តែខ្លួនមិនបានឮពួកគាត់និយាយគ្នាពីរឿងអ្វីទេ។មួយសន្ទុះក្រោយមកឈ្មោះ [redacted] សេរីឧត្តម ក៏ជិះឡានចេញបាត់ទៅ ប្តីខ្លួនមិនចេញទៅណាទេ។លុះដល់ម៉ោងប្រហែល០៦ល្ងាច ប្តីខ្លួនបានដឹកខ្លួននិងកូនចេញពីផ្ទះមកជួយលក់ម្តាយក្មេកខ្លួន។ប្តីខ្លួនអង្គុយលេងបានមួយស្របក់ គាត់បានប្រាប់ខ្លួនថាគាត់ទៅហូបអីនៅហាងតាបារាំង(សារឌី)។ប្រហែលជាម៉ោង១២រំលងអាធ្រាតខ្លួនបានទូរសស័ព្ទទៅប្តី គាត់ប្រាប់ថាគាត់នៅខារ៉ាអូខេ។ពេលគាត់ចេញពីខារ៉ាអូខេគាត់មកដឹកខ្លួននិងកូនមកដេកនៅផ្ទះ(ហាងម្លប់ទឹកដោះគោ)វិញទាំងអស់គ្នា។ក្នុងពេលរៀបដេកនោះខ្លួនបានឮសម្លេងឡាន ខ្លួនគិតថាឡាននោះចូលផ្ទះរបស់ឈ្មោះ ប៉ូលី ។ខ្លួនសូមបញ្ជាក់ថានៅថ្ងៃទី០៩-០៩-២០១២ ខ្លួនមិនបានផ្តល់ចម្លើយថា នៅម៉ោង១២អាធ្រាតបានឮសំរឹបជើងមនុស្ស ឬសម្លេងបើកទឹកចេញពីអាង និងបានឃើញមនុស្សបីនាក់ក្នុងនោះមានឈ្មោះឡៃនោះឡើយ ។ពាក្យទាំងអស់នេះមានក្នុងកំនត់ហេតុរបស់នគរបាល គេចេះតែសរសេរ រួចហើយឱ្យខ្លួនអាននិងផ្តិតមេដៃ។ម្យ៉ាងទៀតគេបញ្ឆោះខ្លួនឱ្យឆ្លើយតាមដែលគេចង់បាននោះទៅ គេនឹងឱ្យខ្លួននិងប្តីរួចខ្លួន។

៥-តាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ សាត សឿន, ឈ្មោះគីង ស៊ាងឡៃ, ឈ្មោះថង់ ចាន់ណា ,ឈ្មោះ លីប តេក ឬចង លីបង៉ែត, ឈ្មោះជា គន្ធា និងឈ្មោះកែង សារ៉េត បានបញ្ជាក់ថា នៅយប់ថ្ងៃទី០៩-០៩-២០១២ វេលាម៉ោង០៧(យប់)ឈ្មោះអ៊ាន ប៊ុនហេង បានចូលទៅហូបបាយនៅហាង(សារឌី) ដែលមានអ្នកចូលរួមគឺឈ្មោះ សាត សឿន, គីង ស៊ាងឡៃ, ថង ចាន់ណា , លីប តេក ប្រពន្ធនិងកូនរបស់ឈ្មោះសាត សឿន និងមិត្តភក្រ័ម្នាក់

ទៀតមិនស្គាល់ឈ្មោះ។ហើយបន្ទាប់ពីហូបបាយនៅហាង(សាវឌី)រួចអ្នកទាំងនោះ(លើកលែងតែប្រពន្ធនិងកូនរបស់ឈ្មោះសាត សឿន)បានបន្តទៅច្រៀងខារ៉ាអូខេនៅកាឡាក់ស៊ីរហូតដល់ម៉ោងប្រមាណជា១២យប់ ក៏បំបែកគ្នាទៅផ្ទះរៀង១ខ្លួន ហើយឈ្មោះ[redacted] ប៊ុនហេង បានទៅយកប្រពន្ធ និងកូនពីផ្ទះម្តាយទៅដេកនៅផ្ទះ(ហាងម្ហូបទឹកដោះគោ)វិញ។

៦-តាមចម្លើយរបស់ជនជាប់ចោទ និងតាមការបំភ្លឺរបស់សាក្សីបានបញ្ជាក់ឱ្យឃើញថា នៅថ្ងៃទី០៩-០៩-២០១២ ចាប់ពីម៉ោងប្រហែល៧យប់ រហូតដល់ម៉ោងប្រហែល១២អាធ្រាត ជនជាប់ចោទឈ្មោះ[redacted] ប៊ុនហេង បានចូលរួមហូបបាយ និងច្រៀងខារ៉ាអូខេ ជាមួយមិត្តភ័ក្រដោយពុំបានចេញទៅណាទេ។

៧-តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ[redacted]បានបញ្ជាក់ថា ជនរងគ្រោះឈ្មោះ[redacted] សេរីឧត្តម បានចេញពីផ្ទះនៅវេលាម៉ោងប្រមាណ០៧យប់ ហើយបានដាច់ការទាក់ទងតាមទូរស័ព្ទ នៅក្នុងអំឡុងម៉ោង០៧ និង២០នាទី ដូច្នេះឃើញថា ពេលវេលាដែលជនរងគ្រោះចាកចេញពីផ្ទះរហូតដល់បាត់ការទាក់ទងគ្នាបាននោះជនជាប់ចោទឈ្មោះ[redacted] ប៊ុនហេង មានវត្តមានកំពុងហូបបាយ និងច្រៀងខារ៉ាអូខេឯណោះទេ ដែលជនជាប់ចោទពុំអាចមក-សម្លាប់ជនរងគ្រោះបានឡើយ។

៨-នៅក្នុងការស៊ើបអង្កេត សមត្ថកិច្ចបានចាប់យកក្រណាត់ស្រោមពូកដែលមានស្នាមប្រឡាក់ដែលសង្ស័យថាជាឈាមរបស់ជនរងគ្រោះ ពីផ្ទះរបស់ជនជាប់ចោទ។ប៉ុន្តែតាមប្រកាសលទ្ធផលកោសល្យវិច្ច័យលេខ២១៩៧/C ៥៤B ចុះថ្ងៃទី១៥-១០-២០១២ របស់វិទ្យាស្ថានវិទ្យាសាស្ត្រព្រហ្មទណ្ឌប្រចាំទីក្រុងហូជីមិញ ដែលបានធ្វើកោសល្យវិច្ច័យលើស្នាមប្រឡាក់ទៅលើកំរាលពូកនេះបញ្ជាក់ថាលទ្ធផល អវិជ្ជមានដែលបញ្ជាក់ថាពុំមែនជាស្នាមឈាមមនុស្សឡើយ ដែលបញ្ជាក់ថា ស្នាមប្រឡាក់លើកំរាលពូកដែលរឹបអូសពីផ្ទះជនជាប់ចោទនោះ ពុំមានការពាក់ពន្ធ័និងការស្លាប់របស់ជនរងគ្រោះឡើយ។

៩-គ្មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] ប៊ុនហេង និងឈ្មោះ[redacted] ស្រីវី ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនៈគីរី កាលពីថ្ងៃទី០៨៩-០៩-២០១២ឡើយ។

១០-រឿងក្តីនេះសាលាដំបូងខេត្តរតនៈគីរី បានធ្វើការអង្កេត និងលើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពកលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

១១-សាលក្រមព្រហ្មទណ្ឌលេខ២៥(ខ) ចុះថ្ងៃទី២៨-០៨-២០១៣ របស់សាលាដំបូងខេត្តរតនៈគីរី ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល។

**<u>ហេតុដូចនេះទិនិច្ឆ័យសេចក្តី</u>**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២-១១-២០១៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៥ (ខ) ចុះថ្ងៃទី ២៨-០៨-២០១៣ របស់សាលាដំបូងខេត្តរតនៈគិរី ទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី។ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់។

សេចក្ដីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការណ៍អនុវត្តសាលដីកានេះឲ្យបានសំរេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted]-[redacted] | [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៥
ក្រឡាបញ្ជី
[redacted]